
Kids of Destiny®
Reaching the Next Generation
www.kidsofdestiny.org

## 3.13 ព្រះយេស៊ូវព្យាបាលក្មេងប្រុសម្នាក់

ព្រះយេស៊ូវយាងទៅលើភ្នំមួយជាមួយសិស្សបីនាក់របស់ទ្រង់។ វាជាពេលវេលាដ៏ពិសេសមួយនៅពេលដែលពួកគេបានឮសម្លេងរបស់ព្រះអម្ចាស់ថា "នេះគឺជាព្រះរាជបុត្រារបស់អញ ចូរស្តាប់ទ្រង់ចុះ" ឥឡូវនេះពួកគេបានចុះពីលើភ្នំហើយ ។ ព្រះអម្ចាស់ទ្រង់មានការងារជាច្រើនទៀតសម្រាប់ព្រះយេស៊ូវធ្វើ ។ ពេលពួកគេចុះពីលើភ្នំ ព្រះយេស៊ូវទ្រង់បានទតឃើញពួកសិស្សឯទៀត ។ មានហ្វូងមនុស្សយ៉ាងច្រើននៅជុំវិញពួកគេ។ នៅទីនោះ ក៏មានពួកអាចារ្យផងដែរ។ ពួកអាចារ្យគឺជាក្រុមមនុស្ស ដែលសរសេរអ្វីគ្រប់យ៉ាងដែលបានកើតឡើង។ ពួកគេតែងតែមមាញឹកនឹងការងាររបស់ពួកគេណាស់ កាលប្រជាជនបានឃើញព្រះយេស៊ូវ គេនាំគ្នារត់មករកព្រះអង្គ ហើយទូលសួរសុខទុក្ខព្រះអង្គ ។ ព្រះយេស៊ូវសួរពួកអាចារ្យថា៖ «តើអ្នករាល់គ្នាជជែកគ្នាអំពីរឿងអ្វី?» ។

ក្នុងចំណោមបណ្ដាជនមានបុរសម្នាក់ទូលព្រះយេស៊ូវថា៖ «លោកគ្រូ! ខ្ញុំមានកូនប្រុសម្នាក់ដែលត្រូវវិញ្ញាណអាក្រក់ចូល វិញ្ញាណនេះធ្វើឱ្យកូនខ្ញុំគនិយាយមិនកើត ហើយវាបណ្តាលឱ្យកូនខ្ញុំដួលប្រកាច់ ខាំធ្មេញជាប់ ហើយខ្លួនរបស់វារឹងតែម្តង ។ ខ្ញុំបានប្រាប់សិស្សលោកដែរ អំពីរឿងនេះប៉ុន្តែពួកគេមិនអាចជួយបានទេ។ ព្រះយេស៊ូវមានបន្ទូលទៅពួកសិស្សថា៖ «អ្នកទាំងអស់គ្នាដែលគ្មានជំនឿអើយ! តើត្រូវឱ្យខ្ញុំនៅជាមួយអ្នករាល់គ្នាដល់ពេលណាទៀត?» ។ ព្រះយេស៊ូវទ្រង់មានបន្ទូលទៅបុរសនោះថា៖ «ចូរនាំក្មេងនោះមកឱ្យឯខ្ញុំ» ។

ពេលដែលក្មេងប្រុសនោះបានចូលមកជិតព្រះយេស៊ូវ វិញ្ញាណអាក្រក់ក៏ចាប់ផ្តើមធ្វើទុក្ខគាត់ម្តងទៀត ។ វិញ្ញាណបានធ្វើឱ្យក្មេងប្រុសញ័របញ្ជ័រ ហើយដួលទៅលើដី បែកពពុះមាត់ទៀតផង ។ វាមើលទៅគួរឱ្យអាសូរ និងគួរឱ្យខ្លាចខ្លាំងណាស់ ។ ព្រះយេស៊ូវបានសួរឪពុកថា តើរឿងនេះបានកើតឡើង ដល់កូនប្រុសរបស់គាត់យូរប៉ុណ្ណាហើយ? ឪពុកឆ្លើយថា៖ «រឿងនេះបានកើតឡើងចំពោះវាតាំងពីវានៅក្មេងមកម្ល៉េះ ។ វិញ្ញាណអាក្រក់នេះបានផ្តួល កូនប្រុសរបស់ខ្ញុំទៅក្នុងភ្លើង និងចូលទៅក្នុងទឹកជាច្រើនដង ។ វិញ្ញាណអាក្រក់នេះបានព្យាយាមសម្លាប់វា ។ ប្រសិនបើលោកអាចធ្វើអ្វីបាន សូមជួយកូនប្រុសខ្ញុំផង!"

ព្រះយេស៊ូវមានបន្ទូលទៅបុរសនោះថា "ខ្ញុំបានឮលោកនិយាយថា ប្រសិនបើ ដូច្នេះ?" អ្វីៗទាំងអស់នឹងកើតឡើងដល់អ្នកណាដែលជឿ និងទុកចិត្តលើខ្ញុំប៉ុណ្ណោះ។ ឪពុកនោះបានស្រែកយំយ៉ាងខ្លាំងថា "លោកម្ចាស់អើយ ខ្ញុំជឿហើយ សូមជួយខ្ញុំប្របាទដែលជាអ្នកមិនជឿនេះផង" ព្រះយេស៊ូវទ្រង់បានបញ្ជាវិញ្ញាណអាក្រក់ ដែលធ្វើឱ្យក្មេងនោះគថ្លង់ ឱ្យចេញពីក្មេងនោះ ហើយកុំឱ្យមករំខានគាត់ទៀតឱ្យសោះ ។ ពេលវិញ្ញាណរៀបនឹងចេញទៅ វាធ្វើឱ្យក្មេងប្រុសនោះប្រកាច់ប្រកិនយ៉ាងខ្លាំង ។ នៅពេលដែលវិញ្ញាណអាក្រក់ទៅបាត់ហើយ ក្មេងប្រុសនោះក៏ដេកស្តូកស្តឹង ។ មនុស្សជាច្រើននិយាយគ្នាថា "គាត់បានស្លាប់ហើយ" ។

ព្រះយេស៊ូវចាប់ដៃក្មេងប្រសុនោះ ហើយលើកឡើង គាត់ក៏បានជាសះស្បើយ។ ពួកសិស្សបានសួរព្រះយេស៊ូវពេលក្រោយថា ហេតុអ្វីបានជាពួកគេមិនអាចដេញអារក្សនោះបាន ។ ព្រះយេស៊ូវទ្រង់មានបន្ទូលតបថា៖ « វិញ្ញាណប្រភេទនេះពុំអាចដេញបានទេ ទាល់តែអធិស្ឋានទៅកាន់ព្រះអម្ចាស់ជាព្រះវរបិតាទើបបាន »។ ពួកគេបានធ្វើដំណើរពីទីនោះ ហើយចាប់ផ្តើមឆ្លងកាត់ស្រុកកាលីឡេ ។ ព្រះយេស៊ូវត្រូវការបង្រៀនសិស្សបន្ថែមទៀត និងរៀបចំពួកគេសម្រាប់ការងារនាពេលអនាគតទៀត ។

**ម៉ាកុស ៩**

## 3.13 ព្រះយេស៊ូវព្យាបាលក្មេងប្រុសម្នាក់- សេចក្តីណែនាំសម្រាប់គ្រូបង្រៀន កំណត់សម្គាល់

១) ព្រះយេស៊ូវទើបតែយាងត្រឡប់ពីលើភ្នំវិញ នៅទីនោះហើយដែលព្រះអង្គ និងសិស្សរបស់ព្រះអង្គបីនាក់ទៀត បានឮព្រះអម្ចាស់មានបន្ទូលមកកាន់ព្រះអង្គ។ ពេលព្រះយេស៊ូវយាងចុះពីលើភ្នំមកវិញ ព្រះយេស៊ូវទតឃើញសិស្សឯទៀតៗ នៅជាមួយហ្វូងមនុស្សជាច្រើន ។

២) មានបុរសម្នាក់នៅក្នុងចំណោមហ្វូងមនុស្សជាមួយកូនប្រុសរបស់គាត់។ ក្មេងប្រុសនោះមានវិញ្ញាណអាក្រក់ចូលហើយធ្វើបាបគាត់ជាខ្លាំង។ ឪពុករបស់ក្មេងនោះចង់ឲ្យព្រះយេស៊ូវព្យាបាលគាត់។

៣) ព្រះយេស៊ូវបានឱ្យបុរសនោះនាំក្មេងមកឯទ្រង់។ វិញ្ញាណអាក្រក់ក៏ធ្វើឱ្យក្មេងប្រុសនោះដួលទៅនឹងដី ហើយប្រកាច់ ។

៤) ឪពុកបាននិយាយថា "បើសិនលោកអាចធ្វើអ្វីបាន សូមជួយកូនប្រុសខ្ញុំផង" ព្រះយេស៊ូវតបថា ហេតុអ្វីលោកនិយាយថាប្រសិនបើដូច្នេះ? អ្វីៗទាំងអស់នឹងកើតឡើងដល់អ្នកណាដែលជឿ និងទុកចិត្តលើខ្ញុំប៉ុណ្ណោះ បុរសនោះតបថា លោកម្ចាស់អើយ ខ្ញុំជឿហើយ សូមជួយខ្ញុំប្រឆាំងដែលជាអ្នកមិនជឿនេះផង ។

៥) ព្រះយេស៊ូវបានបណ្តេញវិញ្ញាណអាក្រក់ឱ្យចាកចេញពីក្មេងនោះទៅ។ ទោះបីក្មេងនោះមើលទៅដូចជាស្លាប់ក៏ដោយក៏ព្រះយេស៊ូវបានចាប់ដៃ ហើយលើកគាត់ឡើង។ គាត់ក៏បានជាសះស្បើយឡើង ។

### សំណួរ

១) មានបុរសម្នាក់មកជាមួយកូនប្រុសរបស់គាត់នៅក្នុងហ្វូងមនុស្ស។ តើបុរសនោះចង់បានអ្វីពីព្រះយេស៊ូវ?

២) តើក្មេងប្រុសនោះមានបញ្ហាអ្វី?

៣) តើឪពុកបាននិយាយទៅព្រះយេស៊ូវយ៉ាងដូចម្តេច ?

៤) តើព្រះយេស៊ូវតបទៅបុរសនោះយ៉ាងដូចម្តេច ?

៥) តើមានអ្វីកើតឡើងចំពោះក្មេងប្រុសនោះ នៅពេលដែលព្រះយេស៊ូវទ្រង់បានបណ្តេញវិញ្ញាណអាក្រក់ ឱ្យចេញពីគាត់?

### ចម្លើយ

១) បុរសនៅក្នុងហ្វូងមនុស្សនោះចង់ឲ្យព្រះយេស៊ូវព្យាបាលកូនប្រុសរបស់គាត់ ។

២) ក្មេងប្រុសនោះមានវិញ្ញាណអាក្រក់ចូល ។

៣) ឪពុកបាននិយាយថា "បើសិនជាលោកអាចធ្វើអ្វីបាន សូមជួយកូនប្រុសខ្ញុំផង"

4) ព្រះយេស៊ូវតបថា ហេតុអ្វីលោកនិយាយថា ប្រសិនបើ ដូច្នេះ? អ្វីៗទាំងអស់នឹងកើតឡើងដល់អ្នកណាដែលជឿ និងទុកចិត្តលើខ្ញុំប៉ុណ្ណោះ ។

៥) ក្មេងប្រុសនោះមើលទៅដូចជាស្លាប់ពេលដែលវិញ្ញាណអាក្រក់ចេញទៅប៉ុន្តែព្រះយេស៊ូវចាប់ដៃក្មេងប្រុសនោះលើកឡើង។ គាត់ក៏បានជាសះស្បើយឡើង ។


Kids of Destiny
Reaching the Next Generation